# មាតិកា

**<u>សេចក្តីកែតម្រូវ</u>**

ដោយមានកំហុសខាងបច្ចេកទេសកុំព្យូទ័រ អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ដែលបានចុះក្នុងរាជកិច្ចលេខ ២២ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៦ ទំព័រ ១៦២០ ត្រង់ចំណុច :

**មាត្រា ២** បន្ទាត់ទី ២ *(ដែលមានទីតាំងស្ថិតនៅសង្កាត់រាម ខណ្ឌព្រៃនុប ....)*

***<u>សូមកែតម្រូវ:</u>*** (ដែលមានទីតាំងស្ថិតនៅ<u>សង្កាត់រាម និង សង្កាត់បិតត្រាំង</u> ខណ្ឌព្រៃនុប....)

អាស្រ័យហេតុនេះ សូមសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាអធ្យាស្រ័យ ។

*សូមអរគុណ !*

## I. ខុទ្ទកាល័យព្រះមហាក្សត្រ

### ១. ព្រះរាជក្រម

០៧-៤-២០០៦ -ព្រះរាជក្រម នស/រកម/០៤០៦/០០៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពី វិសោធនកម្មច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ២០៣៥

### ២. ព្រះរាជក្រឹត្យ

៣១-៣-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៣០៦/១៤២ ស្តីពីការសំរួលភារកិច្ចឯកឧត្តម **ឃឹម សិលា** និង ប្រគល់ភារកិច្ចឯកឧត្តម ឧត្តមសេនីយ៍ឯក **ឡូយ សុផាត** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលខេត្តស្ទឹងត្រែង ២០៣៩

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៤៥ ស្តីពីការតែងតាំងលោក និងលោកស្រីចំនួន ០៥ រូប ជាទីប្រឹក្សាឯកឧត្តម **នេពា ខន** អនុប្រធាន ទី ២ ព្រឹទ្ធសភា នីតិកាលទី ២ ២០៤១

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៤៦ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឧកញ៉ា **ឈេន ថារី** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ២០៤២

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៤៩ ស្តីពីការតែងតាំងឯកឧត្តម **ស៊ិន ឫទ្ធី** បច្ចុប្បន្នអគ្គនាយករងកិច្ចការរដ្ឋបាល ជាអគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រសួងធនធានទឹក និងឧតុនិយម ជំនួសឯកឧត្តម **ណឹ លន់** ដែលត្រូវបានទៅបំពេញភារកិច្ចថ្មី ២០៤៣

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៥១ ស្តីពីការតែងតាំងលោក **គិត សែនសូរិយា** ជា ឧកញ៉ា ២០៤៤

## II~ក្រុមប្រឹក្សាធម្មនុញ្ញ

០៧-៤-២០០៦ -សេចក្តីសំរេចលេខ ០៧៥/០០២/២០០៦ កបធ.ច ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ២០៤៥

## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ

០៦-៤-២០០៦ -អនុក្រឹត្យលេខ ៣១អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសុខាភិបាល ២០៤៧

០៧-៤-២០០៦ -អនុក្រឹត្យលេខ ៣២អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២០៤៩

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០១ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥១

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០២ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៣

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៣ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៤

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៤ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៥

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៥ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៧

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៦ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៨

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៧ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៥៩

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៨ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៦០

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២០៩ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៦២

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១០ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២០៦៣

### ២~សេចក្តីសំរេច

០៤-៤-២០០៦ -សេចក្តីសម្រេចលេខ ១០ សសរ ស្តីពីការបង្កើតគណៈកម្មាធិការតម្រែតម្រង់ទិស សម្រាប់ផ្តល់នូវការណែនាំនូវគោលនយោបាយ និង យុទ្ធសាស្ត្រនានា ដល់ការអនុវត្ត គម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹង ទន្លេសាប ក្នុងក្របខ័ណ្ឌជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ២០៦៤

## IV~ការងារបណ្តាក្រសួង

### ១~ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣០-៣-២០០៦ -ប្រកាសលេខ ១៥៤ សហវ.ប្រក ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក ២០៦៨

## ២_ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

២៣-០២-២០០៦ -លិខិតលេខ ៥៨៣ ពណ.នតត ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អាយ.ឌី** ២០៨៧

២៣-០២-២០០៦ -លិខិតលេខ ៥៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស្កាត (ខេមបូឌា)** ២០៨៩

២៤-០២-២០០៦ -លិខិតលេខ ៥៨៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចំប៉ា ខេមបូឌាន ហាឌីរ** ២០៩១

២៤-០២-២០០៦ -លិខិតលេខ ៥៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង ហ៊ំរ ត្រេឌីង អេន ឆួរ** ២០៩៣

២៤-០២-២០០៦ -លិខិតលេខ ៥៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេឌីយ៉ែរ ឡាយហ្វ៍** ២០៩៥

២៤-០២-២០០៦ -លិខិតលេខ ៥៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.អិល.ភី ទើលដ៍ ត្រេនស្ព័ត** ២០៩៧

២៤-០២-២០០៦ -លិខិតលេខ ៥៩៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អូរអាស៊ីស ហូថេល & រីហ្សត (ខេមបូឌា)** ២០៩៩

២៤-០២-២០០៦ -លិខិតលេខ ៥៩៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ម៉ាស្ទ័រ ខូល ឌីទេឡុបមេន** ២១០១

២៤-០២-២០០៦ -លិខិតលេខ ៥៩៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាំង ខនស្ត្រាក់សិន អេន ត្រេឌីង គ្រុប** ២១០៣

២៤-០២-២០០៦ -លិខិតលេខ ៥៩៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ទើរអន្តរ ខបភើរេសិន** ២១០៥

២៤-០២-២០០៦ -លិខិតលេខ ៥៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីមើរ វីហ្គាស (ខេមបូឌា) អ៊ីន** ២១០៧

២៤-០២-២០០៦ -លិខិតលេខ ៦០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) រីស៊ើច ម៉ាញនីង អ៊ិនវេសមេន** ២១០៩

២៧-០២-២០០៦ -លិខិតលេខ ៦០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេតា អាត (ខេមបូឌា) លីមីធីត** ២១១១

២៨-០២-២០០៦ -លិខិតលេខ ៦០៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡុង វី គ្រុប** ២១១៣

២៨-០២-២០០៦ -លិខិតលេខ ៦០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សាតភូ អិលធីឌី** ២១១៥

២៨-០២-២០០៦ -លិខិតលេខ ៦០៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ែនចឹច អ៊ីតើរីល (ខេមបូឌា)** ២១១៧

០៣-៣-២០០៦ -លិខិតលេខ ៦៤៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី.អ៊ី.អិល** ២១១៩

០៣-៣-២០០៦ -លិខិតលេខ ៦៥០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មេគង្គ ស៊ីធី ឌីវេឡុបមេន** ២១២១

# ព្រះរាជក្រម

នស/រកម/០៤០៦/០០៨

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមការកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្ម
# ច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ

**មាត្រា មួយ.–**

មាត្រា ១ និងមាត្រា ២ នៃច្បាប់ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម :

**មាត្រា១ .–ថ្មី**

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ ត្រូវដាក់ឱ្យចូលនិវត្តន៍ អាស្រ័យតាមលក្ខខណ្ឌដូចខាងក្រោម :

១-នាយទាហានចាប់ពីថ្នាក់វរសេនីយ៍ឯក និងវរនាវីឯកឡើងទៅ នៅពេលដល់អាយុ ៦០ (ហុកសិប) ឆ្នាំ

២-នាយទាហានថ្នាក់វរសេនីយ៍ទោ និងវរនាវីទោ នៅពេលដល់អាយុ ៥៨ (ហាសិបប្រាំបី) ឆ្នាំ

៣-នាយទាហានចាប់ពីថ្នាក់នាយចំណង់ និងនាយនាវីចំណង់ ដល់ថ្នាក់វរសេនីយ៍ត្រី និងវរនាវីត្រី នៅពេលដល់អាយុពី ៤៣ (សែសិបបី) ឆ្នាំ ទៅ ៥៥ (ហាសិបប្រាំ) ឆ្នាំ ។

៤-នាយទាហានរងចាប់ពីថ្នាក់ពលបាលត្រី និងចក្របាលត្រី ដល់ថ្នាក់ព្រិន្ទបាលឯក និងនាយចក្របាលឯក នៅពេលដល់អាយុពី ៣៨ (សាមសិបប្រាំបី) ឆ្នាំ ទៅ ៤២ (សែសិបពីរ) ឆ្នាំ ។

នាយទាហានថ្នាក់ឧត្តមសេនីយ៍ ឧត្តមនាវីវរជន និងវរសេនីយ៍ឯក កងទ័ពជើងអាកាស វរនាវីឯកកងទ័ពជើងទឹក ដែលមានគុណសម្បត្តិនិងសមត្ថភាព ឬជាអ្នកជំនាញឯកទេស ទោះបីដល់អាយុចូលនិវត្តន៍ក៏ដោយ តាមការស្នើសុំរបស់សាមីខ្លួន ដោយមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬតាមតម្រូវការចាំបាច់របស់រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចត្រូវរក្សាទុកដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ប្រទេសជាតិ ។

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទ អាចស្នើសុំចូលនិវត្តន៍មុនពេលកំណត់បាន ។

លក្ខខណ្ឌ និងបែបបទនៃការចូលនិវត្តន៍តាមការកំណត់និងការចូលនិវត្តន៍មុនពេលកំណត់ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ២ .- ថ្មី

យោធិនអាជីពទាំងពីរភេទនៃកងយោធពលខេមរភូមិន្ទអាចទទួលរបបសោធននិវត្តន៍បាន ត្រូវមានលក្ខខណ្ឌដូចខាងក្រោម :

ក-របបសោធននិវត្តន៍អប្បបរមា

១-ចំពោះយោធិនអាជីព ដែលបានបំរើការងារនៅតំបន់លំបាក ការងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១០ (ដប់) ឆ្នាំ ចំពោះបុរស និងយ៉ាងតិច ៨ (ប្រាំបី) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំរើការងារមិនប៉ះពាល់ដល់សុខភាព ឬ គ្រោះថ្នាក់ផ្សេងៗចំនួន ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងចំនួន ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

ខ-របបសោធននិវត្តន៍អតិបរមា

១-ចំពោះយោធិនអាជីព ដែលបានបំរើការងារនៅតំបន់លំបាក ការ

ងារគ្រោះថ្នាក់ ឬការងារប៉ះពាល់សុខភាពយ៉ាងតិច ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះបុរស និង យ៉ាងតិច ១២ (ដប់ពីរ) ឆ្នាំ ចំពោះនារី ។

២-ចំពោះយោធិនអាជីពដែលបានបំពីការងារមិនប៉ះពាល់ដល់សុខភាព ឬគ្រោះថ្នាក់ផ្សេងៗលើសពី ២០ (ម្ភៃ) ឆ្នាំ ចំពោះបុរស និងលើសពី ១៥ (ដប់ប្រាំ) ឆ្នាំ ចំពោះនារី ។

៣-ចំពោះឧត្តមសេនីយ៍ ឧត្តមនារី ឬវីរជនក្នុងកងយោធពលខេមរភូមិន្ទដែលបានបំពេញលក្ខខណ្ឌដូចមានចែងនៅចំណុច (ក) ខាងលើ ត្រូវបានទទួលរបបសោធននិវត្តន៍អតិបរមា ។

៤-ចំពោះយោធិនពិការ ដែលនៅបំពីការងារជាប់រហូតដល់អាយុចូលនិវត្តន៍ ។

ដោយឡែក លក្ខខណ្ឌ បែបបទស្តីពីរបបឧបត្ថម្ភចំពោះយោធិនពិការដែលបំពីការងារមិនបាន យោធិនពលី មរណៈ បង្កស្លាប់ និងបាត់ខ្លួនត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ពីរ.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០៦

នស/រកម.០៤០៦.០១២ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**
**ហត្ថលេខា**
**ទៀ បាញ់**

លេខៈ ១៦១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុខ គាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៦/១៤២

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** ត្រូវបានសំរួលភារកិច្ចឯកឧត្តម **ឃឹម សិលា** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៤ ពីអភិបាលខេត្តស្ទឹងត្រែង ឱ្យទៅបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា២:** ត្រូវបានប្រគល់ភារកិច្ចឯកឧត្តម ឧត្តមសេនីយ៍ឯក **ឡូយ សុផាត** នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាអភិបាលខេត្តស្ទឹងត្រែង ។

**មាត្រា៣:** ឯកឧត្តម **ឡូយ សុផាត** ត្រូវទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំ នៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា៤:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៥:** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៦:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០០៦

**ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាសព្វគ្រាប់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

នស. ០៦០៣. ១៤៤

លេខ: ១៤៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ំ ទី ឆាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៤៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី ១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងថ្នាក់ដឹកនាំព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១: តែងតាំង :

| | |
|---|---|
| ១-លោកស្រី គួ ធឿន | ជាទីប្រឹក្សា ឯកឧត្តម ទេព ងន អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ២ មានឋានៈស្មើ រដ្ឋលេខាធិការ |
| ២-លោក សាយ សុផល | ជាទីប្រឹក្សា ឯកឧត្តម ទេព ងន អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ២ មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៣-លោកស្រី ទេព ស៊ីចាន់ថា | ជាទីប្រឹក្សា ឯកឧត្តម ទេព ងន អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៤-លោកស្រី ទេព ប៊ុរ៉ាមីន | ជាទីប្រឹក្សា ឯកឧត្តម ទេព ងន អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៥-លោកស្រី ថេង រដ្ឋា | ជាទីប្រឹក្សា ឯកឧត្តម ទេព ងន អនុប្រធានទី ២ ព្រឹទ្ធសភា នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ |

មាត្រា ៣: ប្រធានព្រឹទ្ធសភានិងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសម្រេច ។

មាត្រា ២: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៦០៤.១៥១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ . ថ្ងៃទី ៤ ខែមេសា ឆ្នាំ ២០០៦

លេខ: ១៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

ស៊ាន់ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០២/១៤៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

**ប្រោសព្រះរាជទាន**

ចំពោះ

ឧកញ៉ា **ឈេន ថាវី**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៦០៤.១៥៧

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៥១ . ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៤៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្ដម ស៊ិន វុទ្ធី បច្ចុប្បន្នអគ្គនាយករងកិច្ចការរដ្ឋបាល ជាអគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងធនធានទឹក និងឧតុនិយម ជំនួសឯកឧត្ដម ណើ លន់ ដែលត្រូវបានទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤:** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

៣រល.០៦០៤.១៥៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២ ខែមេសា ឆ្នាំ ២០០៦

លេខ ៦៤៥ .ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ៧ ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

នស/រកត/០៤០៦/១៥១

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

## តែងតាំង

លោក គិត សែនសូរិយា

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល-០៦០៤.១៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០០៦

លេខ: ១៥០ ច.ល
បានឃើញ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាអ៊ី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១០៣/០០៣/២០០៦

ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦

**សេចក្តីសម្រេច**

លេខ : ០៧៥/០០២/២០០៦ កបធ.ច

ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/១០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ប្រកាសឱ្យប្រើច្បាប់ស្តីពីការយល់ព្រម និង ការអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិ ចែងពីការទទួលស្គាល់ និង ការប្រតិបត្តិនូវសេចក្តីសម្រេចមជ្ឈត្តករបរទេស
- បានឃើញសំណើលេខ ៣០០ រស ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័តយល់ព្រមកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមឱ្យរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិតលេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ ២០០៦ ។ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលសំណើនេះ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ វេលាម៉ោង ១០:៤០ នាទី ព្រឹក ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់របាយការណ៍បន្ថែមរបស់តំណាងក្រសួងពាណិជ្ជកម្ម**

**ក្រោយពីបានពិភាក្សាតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី វាក្យខ័ណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភា បានអនុវត្តយ៉ាងត្រឹមត្រូវ តាមបែបបទដែលមានចែងក្នុងមាត្រា ១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យ អនុម័តច្បាប់នេះ
- យល់ឃើញថា មាត្រា ៥ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបកស្រាយថា តុលាការអាចធ្វើអន្តរាគមន៍ បានក្នុងករណីដែលភាគីស្នើសុំ ហើយមិនកម្រិតអំណាចរបស់តុលាការឡើយ
- យល់ឃើញថា មាត្រា ៤២ នៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលបានប្រគល់សិទ្ធិឱ្យសាលាឧទ្ធរណ៍សម្រេច លើការប្តឹងជំទាស់ ការទទួលស្គាល់ និងការដាក់ឱ្យអនុវត្តមជ្ឈត្តវិនិច្ឆ័យ បានតែក្នុងករណីដែលតុលាការពាណិជ្ជកម្ម មិនទាន់បានបង្កើត
- យល់ឃើញថា ខ្លឹមសារនៃច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ក្រៅពីមាត្រា ៥ និងមាត្រា ៤២ ដែលបានកត់ សម្គាល់ខាងលើ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ

**សម្រេច**

**មាត្រា ១.-** ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ ហើយព្រឹទ្ធសភាក៏បានយល់ព្រមអោយរដ្ឋសភាបន្តនីតិវិធីតាមរយៈលិខិត លេខ ០១៧/០៣០៦/ពស/នវ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០០៦ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គរបស់ ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែល មានចែងក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

ឧ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ប៊ិន ឈិន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើតនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល ។

**មាត្រា ២.-**

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិមានបេសកកម្មដូចតទៅ :

- ទំនាក់ទំនងជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការសម្របសម្រួលកិច្ចសហការប្រតិបត្តិការអន្តរជាតិលើវិស័យសុខាភិបាល

- ទំនាក់ទំនងសម្របសម្រួលការងារអាស៊ាន សម្របសម្រួលកិច្ចការអង្គការពាណិជ្ជកម្មពិភពលោក ដែលពាក់ព័ន្ធនឹងវិស័យសុខាភិបាល
- ពង្រឹងកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលទំនាក់ទំនងជាមួយអង្គការជាតិ-អន្តរជាតិ អង្គការសង្គមស៊ីវិល បណ្តាប្រទេសនានា ដែលជួយវិស័យសុខាភិបាលកម្ពុជា
- សម្របសម្រួល និងគ្រប់គ្រងទិន្នន័យព័ត៌មានជំនួយ និងកម្មវិធីនៃគម្រោងកម្មវិធីសកម្មភាពសុខាភិបាល របស់ភាគីដៃគូ សហប្រតិបត្តិការ តាមរយៈការចុះបញ្ជិកា ពិធីសារ ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីធានាពីភាពស៊ីសង្វាក់ សុខដុមណីយកម្ម និងភាពជាម្ចាស់ ព្រមទាំងសរុបរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួង ។

**មាត្រា ៣.-**

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាន មួយចំនួនជាជំនួយការតាមការចាំបាច់ ។

រចនាសម្ព័ន្ធ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រី ក្រសួងសុខាភិបាល**

**វេជ្ជបណ្ឌិត នុត សុខុម**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ : ៣២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣.០៧៥ លានរៀល (បីពាន់ចិតសិបប្រាំលានរៀលគត់ )ពីជំពូក ៤០ (ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) ជូនក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់បំណុលថ្លៃផលិតសំបកកាតអត្តសញ្ញាណប័ណ្ណ និង ថ្លៃផលិតអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនក្រុមហ៊ុន **ហ្គោលដែនឆៃណាគ្រុប**។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ០៤ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តក្រចេះ ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម :

១- លោក **សុខ រ៉ាឃាំ** ឋានន្តរសក្តិ វរមន្ត្រី ថ្នាក់លេខ ១០ ពីអភិបាលរងខេត្ត ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល

២- លោក **អ៊ុំ ម៉ូរិន្ទ** មន្ត្រីក្របខ័ណ្ឌក្រសួងអប់រំយុវជន និងកីឡា ពីអភិបាលរងខេត្ត អោយទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

៣- លោកស្រី **ជុន ចំណាន** មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា ពីអភិបាលរងខេត្ត ឱ្យទៅបំរើការងារនៅអង្គភាពដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**<u>កន្លែងទទួល</u> :**

*ក្រសួងព្រះបរមរាជវាំង*
*អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*អគ្គលេខាធិការរាជរដ្ឋាភិបាល*
*ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*(ដើម្បីជូនជ្រាប)*
*ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
*ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ** ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តស្ទឹងត្រែង ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក ឌៀប ណារ៉េត ឋានន្តរសក្តិ ព្រិន្ទបាលទោ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងខេត្ត អោយទៅបំរើការងារនៅអង្គភាពដើមវិញ

២- លោក ទាំ ឱុត្តារ៉ា ពីអភិបាលរងខេត្តស្ទឹងត្រែង ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចពីអភិបាលរងខេត្តមណ្ឌលគិរី នូវមន្ត្រីចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **សុខ រុន**

២- លោក **ស្រេង ឫទ្ធា** ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តព្រះវិហារ ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឃ៉ល់ សាន្ត** ឋានន្តរសក្តិ ឧត្តមមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលរងទី១ខេត្ត អោយមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និង ថ្នាក់ដដែល

២- លោក **មាស សារឿន** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ពីអភិបាលរងខេត្ត អោយទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

៣- លោក **ញ៉ៃ ម្នូន** ឋានន្តរសក្តិ ពលបាលឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងខេត្ត អោយទៅបំរើការងារនៅអង្គភាពដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តរតនគីរី ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **ហេង សំអាន** ពីអភិបាលរងខេត្ត ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល

២- លោក **ស៊ុម ស៊ូយុទ** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១៣ ពីអភិបាលរងខេត្ត ឱ្យមកបំរើការងារនៅទីស្តីការក្រសួងមហាផ្ទៃ ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២០៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តសៀមរាប ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក អ៊ុក ធី មន្ត្រីក្របខ័ណ្ឌក្រសួងផែនការ ពីអភិបាលរងខេត្ត ឱ្យទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

២- លោក តូច សារូ ពីអភិបាលរងខេត្តសៀមរាប ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០៦

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៤០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **សាន វណ្ណា** មន្ត្រីក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ពីអភិបាលរងខេត្តឧត្តរមានជ័យ អោយទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ២០៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តបាត់ដំបង ចំនួន ០៣រូប ដូចមានរាយនាមខាងក្រោម :

១- លោក **ស៊ុយ ម៉ិនមេង** មន្ត្រីក្របខ័ណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីអភិបាលរងខេត្ត ឱ្យទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

២- លោក **ស៊ូ អារ៉ាវ៉ាត់** មន្ត្រីក្របខ័ណ្ឌក្រសួងបរិស្ថាន ឱ្យទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

៣- លោក **ចក់ ចិន្តា** បានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ពីអភិបាលរងខេត្ត អោយទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (<u>ដើម្បីជូនជ្រាប</u>)*
- *ដូចមាត្រា ៣ (<u>ដើម្បីអនុវត្ត</u>)*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ២០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចលោក **តូ ធានី** មន្ត្រីក្របខ័ណ្ឌនគរបាលជាតិ ពីអភិបាលរងខេត្តបន្ទាយមានជ័យ ឱ្យទៅបំរើការងារនៅអង្គភាពដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៣ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២១០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចអភិបាលរងខេត្តពោធិ៍សាត់ ចំនួន ០២រូប ដូចមានរាយនាមខាងក្រោម :

១- លោក **នង ឌីណាល់** ឋានន្តរសក្តិ វរសេនីយ៍ទោ នៃក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ពីអភិបាលរងខេត្ត ឱ្យទៅបំរើការងារនៅក្នុងក្របខ័ណ្ឌដើមវិញ

២- លោក **ជា ផលទីរៈ** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ពីអភិបាលរងខេត្ត ឱ្យទៅបំរើការងារនៅអង្គភាពដើមវិញ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៦*

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៣ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១០ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការតម្រែតម្រង់ទិស សម្រាប់ផ្តល់នូវការណែនាំពីគោលនយោបាយ និង យុទ្ធសាស្ត្រនានា ដល់ការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្ត ជុំវិញបឹងទន្លេសាប ក្នុងក្របខណ្ឌជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៨/១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ-បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ
- បានឃើញកិច្ចព្រមព្រៀងផ្តល់ជំនួយឥតសំណងលេខ 0034-CAM(SF) ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ២០០៦ រវាងរាជរដ្ឋាភិបាលកម្ពុជា និង ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មាធិការតម្រែតម្រង់ទិសសម្រាប់ផ្តល់ការណែនាំពីគោលនយោបាយ និងយុទ្ធសាស្ត្រនានា ដល់ការអនុវត្តគម្រោងជំនួយឥតសំណងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ ០០៣៤ CAM(SF) ស្ថិតនៅក្រោមការគប់គ្រងផ្ទាល់របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **នួច ភានុន** | អគ្គលេខាធិការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ | ប្រធាន |
| ២-លោក **លេខ ទី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងជាប្រធាននាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- លោក **ឈៅ ធួក** | ប្រធាននាយកដ្ឋានជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤- លោកបណ្ឌិត **ចាន់ ដារ៉ុង** | អគ្គនាយករងបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៥- លោក **សុខ ស៊ីនូ** | មន្ត្រីនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | លេខាធិការ |
| ៦- ឯកឧត្តម **វន្ថី ចិរៈ** | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៧- ឯកឧត្តម **គល់ ចន្ថរ៉ា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | សមាជិក |
| ៨-លោក **តឹកកីអែ សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩-លោកបណ្ឌិត **នៅ បោនន់** | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ១០-លោកស្រី **ជុត លាវខាន់ឌី** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសមភាពយេនឌ័រ និងអភិវឌ្ឍសេដ្ឋកិច្ច នៃក្រសួងកិច្ចការនារី | សមាជិក |
| ១១-លោក **រស់ បរម** | អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២.-**

តួនាទី និង ភារកិច្ច

***គណៈកម្មាធិការ***

- ដឹកនាំ និង សម្របសម្រួលការអនុវត្តគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាបតាមខ្លឹមសារនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីជំនួយឥតសំណងលេខ ០០៣៤ CAM(SF) ចុះថ្ងៃទី០៩ ខែ មិនា ឆ្នាំ២០០៦

- ផ្តល់គោលនយោបាយ និងយុទ្ធសាស្ត្រផ្សេងៗដល់ភ្នាក់ងារប្រតិបត្តិគម្រោងទាំងអស់ ដែលពាក់ព័ន្ធនឹងគម្រោងទ្រទ្រង់ជីវភាពប្រជាជនប្រកបដោយនិរន្តរភាពនៅតាមបណ្តាខេត្តជុំវិញបឹងទន្លេសាប
- ជំរុញការអនុវត្តគម្រោងនានា អោយទទួលបានលទ្ធផលតាមផែនការសកម្មភាពការងារ
- ធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង
- សម្របសម្រួល និងដោះស្រាយបញ្ហាទាំងឡាយដែលអាចកើតមានឡើងក្នុងការអនុវត្តគម្រោង និងវិវាទដែលពាក់ព័ន្ធនឹងតួនាទីរបស់សាមីក្រសួងនិមួយៗក្នុងក្របខណ្ឌគម្រោង ក្នុងករណីចាំបាច់ត្រូវលើកសំណើជូនរាជរដ្ឋាភិបាល
- ដើរតួនាទីជាអ្នកគាំទ្រ និងសហការក្នុងការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាពតាមគ្រប់មធ្យោបាយ ។

*ប្រធាន*

- ជំរុញការអនុវត្តតួនាទី និងភារកិច្ចខាងលើឱ្យបានទទួលលទ្ធផលល្អប្រសើរ
- ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់គណៈកម្មាធិការ
- កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញ របស់គណៈកម្មាធិការ
- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ព័ន្ធនឹងគម្រោងនេះ
- ធានាអោយមានទំនាក់ទំនងល្អរវាងគណៈកម្មាធិការតម្រែតម្រង់ទិសគម្រោង និងទីស្តីការគណៈរដ្ឋមន្ត្រី
- មានសិទ្ធិអញ្ជើញប្រធានក្រុមសម្របសម្រួលគម្រោងថ្នាក់ខេត្តមកប្រជុំ និង ធ្វើបទបង្ហាញពីលទ្ធផលការងារជូនគណៈកម្មាធិការ

*អនុប្រធាន*

- ត្រូវបំពេញរាល់កិច្ចការដែលប្រធានប្រគល់អោយ
- ទទួលខុសត្រូវជាទូទៅលើការងាររបស់គណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន
- អនុវត្តន៍តួនាទី និងភារកិច្ចដូចមានចែងក្នុងតួនាទី និង ភារកិច្ចរបស់សមាជិក។

*លេខាធិការ*

- ត្រូវសហការជាមួយសមាជិកដើម្បីរៀបចំកម្មវិធីរបស់គណៈកម្មាធិការ និងរៀបចំរបៀបវារៈ និងសំណុំឯកសារពាក់ព័ន្ធសម្រាប់អង្គប្រជុំ
- ត្រូវសហការជាមួយសមាជិកដើម្បីរៀបចំប្រជុំបូកសរុបការងារ ឬសិក្ខាសាលា ដើម្បីតាមដាន និង វាយតម្លៃការអនុវត្តគម្រោង និងលើកទិសដៅសំរាប់អនុវត្តបន្ត
- រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹង និង លិខិតរដ្ឋបាល ដាក់ជូនប្រធានចុះហត្ថលេខា ។

*សមាជិក*

- ផ្តល់របាយការណ៍សង្ខេបប្រចាំឆមាស និង ប្រចាំឆ្នាំស្តីអំពីការអនុវត្តការងាររបស់ក្រសួង-ស្ថាប័នរបស់ខ្លួនក្នុងប្រកខ័ណ្ឌគម្រោងនេះ ដាក់ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍

- ស្វែងយល់អំពីផលប៉ះពាល់ជាយុទ្ធសាស្ត្រតាមរយៈលទ្ធផលរបស់គម្រោង
- ទទួលខុសត្រូវរៀបចំផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងគម្រោង និងធ្វើរបាយការណ៍ជូនស្ថាប័នរបស់ខ្លួន
- ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។
- សម្របសម្រួល និង ផ្តល់ជំនាញបច្ចេកទេសឱ្យដល់ភ្នាក់ងារអនុវត្តគម្រោងថ្នាក់ខេត្ត

**ប្រការ៣.-**

គណៈកម្មាធិការតម្រែតម្រង់ទិសនេះ ត្រូវរៀបចំប្រជុំសាមញ្ញយ៉ាងតិច០៦ខែម្តង និងប្រជុំវិសាមញ្ញតាមការចាំបាច់ ហើយត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលប្រជុំដាក់ជូនប្រមុខរាជរដ្ឋាភិបាល និង ម្ចាស់ជំនួយជ្រាប ។

**ប្រការ៤.-**

គណៈកម្មាធិការនេះត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រោមការគ្រប់គ្រងរបស់លេខាធិការនៃគណៈកម្មាធិការ និងមានមន្ត្រីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ មួយចំនួនជាជំនួយការតាមការចាំបាច់ ដោយជ្រើសរើស ដោយប្រធានគណៈកម្មាធិការ ។

**ប្រការ៥.-**

គណៈកម្មាធិការនេះប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។

**ប្រការ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

***កន្លែងទទួល:***
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចក្នុងប្រការ ៦ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ២៥៤ សហវ.ប្រក

លិខិតចូល
ថ្ងៃទី 07 ខែ 4 ឆ្នាំ2006

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែមីនាឆ្នាំ២០០៦

# ប្រកាស

## ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រម នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស. ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស. រកម. ០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ. បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន BIVAC ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១** : ប្រកាសអោយប្រើបទបញ្ញត្តិស្តីពីការអនុវត្តសេវាអធិការកិច្ចទំនិញមុនពេលផ្ទុក ដូចមានខ្លឹមសារក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីប្រកាសនេះ ។

**ប្រការ២** : បទបញ្ញត្តិដែលជាឧបសម្ព័ន្ធនៃសេចក្តីប្រកាសនេះ គឺជាការណែនាំអនុវត្តកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងក្រុមហ៊ុន BIVAC ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីអធិការកិច្ចទំនិញមុនពេលផ្ទុក ។

**ប្រការ៣** : ក្រុមហ៊ុន ឬបុគ្គលទាំងឡាយណាដែលខកខានពុំបានមកសុំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុករាល់មុខទំនិញ លើកលែងតែមុខទំនិញ ដែលមានចែងក្នុងជំពូក២ ប្រការ៣ ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះហើយដែលបានដឹកជញ្ជូនចូលមកដល់ដែនគយនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ស្មើនឹង ៧% (ប្រាំពីរភាគរយ) នៃតំលៃទំនិញសរុបគិតជា CIF ។ ក្នុងករណីចាំបាច់ ការជំរះបែបបទគយសំរាប់ទំនិញ ដែលមិនបានឆ្លងកាត់ PSI អាចនឹងត្រូវបានធ្វើឡើងដោយមានការចូលរួមពីភាគីពាក់ព័ន្ធ ។

**ប្រការ៤** : ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចំលងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ក្រសួងមហាផ្ទៃ
- ក្រសួងពាណិជ្ជកម្ម
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- គ្រប់សាលាខេត្ត- ក្រុង
- ទីចាត់ការគយ និងរដ្ឋាករ
- សភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- ការិយាល័យទំនាក់ទំនងក្រុមហ៊ុន BIVAC នៅកម្ពុជា
- កាលប្បវត្តិ- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№....................MEF/............

រាជធានីភ្នំពេញ , ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៦

# បទបញ្ញត្តិ
(REGULATION)

## ស្តីពី ការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក
(ON THE IMPLEMENTATION OF PRE-SHIPMENT INSPECTION SERVICES)

បទបញ្ញត្តិនេះ គឺជាឧបសម្ព័ន្ធនៃប្រកាសលេខ **១៥៤** សហវ.ប្រក ចុះថ្ងៃទី **៣០** ខែ **មីនា** ឆ្នាំ **២០០៦** របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៍សេវាអធិការកិច្ចទំនិញមុនពេលផ្ទុក ។

## ជំពូកទី ១

## ការបកស្រាយ
(INTERPRETATION)

**ប្រការ ១ : និយមន័យ** (Definition)

១.១: **ទីចាត់ការគយ និងរដ្ឋាករ** (Customs): មានន័យថា ទីចាត់ការគយ និងរដ្ឋាករនៃព្រះរាជាណាចក្រកម្ពុជា ។

១.២: **ប្រតិវេទន៍គយ** (Customs Declaration): មានន័យថា ឯកសារប្រកាសនាំចូលដែលបានបំពេញដោយ អ្នកនាំចូល ដោយផ្អែកលើព័ត៌មានក្នុងរបាយការណ៍ផ្ទាល់ខ្លួន ។

១.៣: **របាយការណ៍មិនស្របគ្នា** (Discrepancy Report): មានន័យថា របាយការណ៍ដែលចេញដោយក្រុមហ៊ុនអធិការកិច្ច ( សំដៅដល់របាយការណ៍ជាក់ស្តែងដែលមិនអាចតវ៉ាបាន ) នៅពេលដែលអធិការកិច្ចទំនិញមុនពេលផ្ទុកចង្អុលបង្ហាញថា មានភាពមិនស្របគ្នារវាងបរិមាណ ឬគុណភាពជាក់ស្តែង ឬទាំងបរិមាណ និងទាំងគុណភាពនៃទំនិញ និងសេចក្តីបញ្ជាក់អំពីយថាប្រភេទទំនិញរបស់អ្នកនាំចូល ។

១.៤: **ការត្រួតពិនិត្យឯកសារ** (Documentary Check): មានន័យថា ការផ្ទៀងផ្ទាត់ដោយក្រុមហ៊ុនអធិការកិច្ចទៅលើ ភាពអាចទទួលបាន តម្លៃ និងចំណាត់ថ្នាក់តារាងពន្ធគយនៃទំនិញនាំចូលតាមរយៈការពិនិត្យលើ ឯកសារ និងព័ត៌មានដែលផ្តល់ដោយអ្នកនាំចូល ឬអ្នកនាំចេញ ។

១.៥: **ទំនិញរួចផុតពីអធិការកិច្ចមុនពេលផ្ទុក** (Exempt Goods): មានន័យថា ទំនិញទាំងឡាយណាដែលមានចែងនៅក្នុងជំពូកទី ២ ប្រការ ៣ នៃបទបញ្ញត្តិនេះ ។

១.៦: **កម្រៃសេវា**(Fees) : មានន័យថា ជាកម្រៃសេវាដែលអ្នកនាំចូលបង់ជូនក្រុមហ៊ុនអធិការកិច្ចសំរាប់ការផ្តល់សេវាធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកដូចមានចែងនៅក្នុងជំពូកទី៤ ប្រការ ៧ ចំណុច ៧.១ ។

១.៧: **ទំនិញ** (Goods): មានន័យថា ទំនិញ និងសេវាពាក់ព័ន្ធទាំងឡាយ ( ក្រៅពីទំនិញរួចផុតពីអធិការកិច្ចដែលមានចែងនៅក្នុងប្រការ ៣ ) ដែលត្រូវបានស្នើសុំនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលមានតម្លៃបញ្ជាទិញចំនួន **៤.៥០០** ដុល្លារអាមេរិក (បួនពាន់ប្រាំរយដុល្លារអាមេរិក) គិតតាមតម្លៃ **FOB** ឬច្រើនជាងនេះ ហើយរួមទាំងការដឹកជញ្ជូនទំនិញ និងសេវាពាក់ព័ន្ធមួយផ្នែកជាមួយនឹងតម្លៃតិចជាង ប៉ុន្តែ បើតម្លៃសរុបនៃការដឹកជញ្ជូនមួយផ្នែកនេះមានតម្លៃ **៤.៥០០** ដុល្លារ អាមេរិកគិតតាមតម្លៃ **FOB** ឬច្រើនជាងនេះ ។

១.៨: **រដ្ឋាភិបាល** (Government) : មានន័យថា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

១.៩: **ការបញ្ជាក់យថាប្រភេទទំនិញរបស់អ្នកនាំចូល** (Importer Specifications) : មានន័យថា សេចក្តីបញ្ជាក់ អំពីយថាប្រភេទទំនិញ ឬនៅពេលគ្មានសេចក្តីបញ្ជាក់អំពីយថាប្រភេទទំនិញទៅលើការរៀបរាប់អំពី មុខទំនិញ ដែលអ្នកនាំចូលបានរាយការណ៍ជូនក្រុមហ៊ុនអធិការកិច្ច ដូចមានចែងក្នុងជំពូកទី ៣ ប្រការ ៤ ចំណុច ៤.១ ។

១.១០: **ក្រុមហ៊ុនអធិការកិច្ច** (Inspection Company): មានន័យថា ក្រុមហ៊ុន BIVAC ដែលបានចុះកិច្ចព្រមព្រៀងនៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៦ ជាមួយរាជរដ្ឋាភិបាលកម្ពុជាដែលជាអ្នកផ្តល់សិទ្ធិឱ្យក្រុមហ៊ុននេះ ធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

១.១១: **ការិយាល័យទំនាក់ទំនងរបស់ក្រុមហ៊ុនអធិការកិច្ច** (Inspection Company Liaison Office): មានន័យថា ការិយាល័យទំនាក់ទំនងតាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនអធិការកិច្ច ដើម្បីសំរបសំរួលអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

១.១២: **ក្រសួងពាណិជ្ជកម្ម** : មានន័យថា ក្រសួងពាណិជ្ជកម្ម នៃរាជរដ្ឋាភិបាលកម្ពុជា ។

១.១៣: **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** : មានន័យថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរាជរដ្ឋាភិបាលកម្ពុជា ។

១.១៤: **អធិការកិច្ចទំនិញមុនពេលផ្ទុក** (PSI) : មានន័យថា អធិការកិច្ចលើបរិមាណ និងគុណភាពទំនិញ និង សកម្មភាពពាក់ព័ន្ធទាំងឡាយ ដែលត្រូវអនុវត្តដោយ ក្រុមហ៊ុនអធិការកិច្ច ។

១.១៥: **បទបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក** (PSI Order " PIO ") : មានន័យថា ឯកសារចេញដោយ និងចុះបញ្ជីនៅការិយាល័យទំនាក់ទំនងរបស់ក្រុមហ៊ុនអធិការកិច្ច ពាក់ព័ន្ធនឹងការដាក់ពាក្យសុំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុករបស់អ្នកនាំចូល ។

១.១៦: **ការផ្ទៀងផ្ទាត់តម្លៃ** (Price Verification) : មានន័យថា ការពិនិត្យផ្ទៀងផ្ទាត់តម្លៃទំនិញទាំងឡាយដើម្បីកំណត់ :

**ក-** ថាតើទឹកប្រាក់ដែលអ្នកលក់ចុះក្នុងវិក្កយបត្រទំនិញនោះ ត្រូវគ្នានឹងតម្លៃទំនិញនាំចេញជាទូទៅក្នុងប្រទេសផ្គត់ផ្គង់ដែរឬទេ ឬក៏ត្រូវគ្នានឹងតម្លៃទំនិញលើទីផ្សារអន្តរជាតិឬទេ ឬត្រូវគ្នានឹងតម្លៃគិតពន្ធគយដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែរឬទេ ។ ក្នុងករណីប្រសិនបើតម្លៃទាំងនោះមិនត្រូវគ្នាទេ ត្រូវបញ្ជាក់បង្ហាញឱ្យឃើញនូវទំហំនៃគម្លាតគ្នាអំពីតម្លៃនោះ។

# ជំពូកទី ២

## គ្រប់ដណ្តប់ការធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក
(SCOPE OF PRE-SHIPMENT INSPECTION)

### ប្រការ ២ : ទំនិញត្រូវធ្វើអធិការកិច្ចមុនពេលផ្ទុក (Goods Subject to PSI)

២.១: ការចាប់ផ្តើម (Commencement)

បទបញ្ញត្តិនេះត្រូវចូលជាធរមានចាប់ពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ តទៅ ។

២.២: ការចុះបញ្ជី និងការងារអធិការកិច្ចទំនិញ (Registration and Inspection of Goods)

ទំនិញទាំងអស់ ក្រៅពីទំនិញរួចផុតពីការធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក ដូចមានចែងនៅក្នុងជំពូកទី ២ ប្រការ ៣ ដែលត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ នេះតទៅ ត្រូវតែមកចុះបញ្ជីនៅការិយាល័យទំនាក់ទំនងរបស់ក្រុមហ៊ុនអធិការកិច្ច ហើយទំនិញទាំងនេះត្រូវធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ដោយក្រុមហ៊ុនអធិការកិច្ចនៅក្នុងប្រទេសផ្គត់ផ្គង់ទំនិញនោះ នៅមុនពេលធ្វើការដឹកជញ្ជូនចូលមកព្រះរាជាណាចក្រកម្ពុជា ។

២.៣: អន្តរកាល (Transitional)

អ្នកនាំចូលទំនិញទាំងឡាយដែលបានកាន់កាប់បែបបទសុំចុះបញ្ជីនាំចូល ( Registered Import Advice) ដែលចេញជូនដោយក្រុមហ៊ុនអធិការកិច្ចចាស់នៅមុនថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ ត្រូវបានអនុញ្ញាតឱ្យបន្ត និងបញ្ចប់ដំណើរការធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកជាមួយក្រុមហ៊ុនអធិការកិច្ចចាស់នោះ ។

### ប្រការ ៣ : ទំនិញរួចផុតពីអធិការកិច្ចទំនិញមុនពេលផ្ទុក (Goods Exempt from PSI)

ទំនិញទាំងឡាយដែលអាចរួចផុតពីអធិការកិច្ចទំនិញមុនពេលផ្ទុក(PSI) មានដូចខាងក្រោម :

ក- ទំនិញមានតម្លៃ FOB តិចជាង ៤.៥០០ (បួនពាន់ប្រាំរយ) ដុល្លារអាមេរិក

ខ- សំភារៈប្រើប្រាស់ក្នុងគេហដ្ឋាន និងតវ៉ាន់ផ្ទាល់ខ្លួន

គ- អំណោយរបស់រដ្ឋាភិបាលបរទេស ឬ អង្គការអន្តរជាតិ ជូនដល់ក្រសួងស្ថាប័ន អង្គការសប្បុរសធម៌ និងអង្គការមនុស្សធម៌ដែលមានការទទួលស្គាល់ជាផ្លូវការ

ឃ- ទំនិញនាំចូលដោយបេសកម្មទូត និង កុងស៊ុល និង សំរាប់ភ្នាក់ងារនានារបស់អង្គការសហប្រជាជាតិដែលត្រូវនាំចូលសំរាប់តម្រូវការផ្ទាល់ខ្លួន

ង- អំណោយជាសម្ភារៈ

ច- ទំនិញនាំចូលសំរាប់រដ្ឋាភិបាលប្រើប្រាស់ ឬក្រោមបញ្ជានាំចូលរបស់រដ្ឋាភិបាល

ឆ- ត្បូងថ្ម និងលោហៈមានតម្លៃប្រណិត

ជ- វត្ថុសិល្បៈ

ឈ- សត្វមានជីវិត

ញ- កញ្ចប់អីវ៉ាន់ផ្ញើតាមប្រៃសណីយ៍ និងវត្ថុគំរូខាងពាណិជ្ជកម្ម

ដ- សំណល់លោហៈ

ឋ- ទំនិញនាំចូលជាបណ្តោះអាសន្ន ( ទំនិញនាំចូលសំរាប់ធ្វើការកែច្នៃសំរាប់ការនាំចេញ )

ឌ- ទំនិញដឹកជញ្ជូនជាអន្តរជាតិឆ្លងកាត់ប្រទេសកម្ពុជា ( នៅក្រោមការត្រួតពិនិត្យរបស់គយ )

ឍ- គ្រឿងផ្ទុះ និងផលិតផលកាំជ្រួច

ណ- គ្រាប់រំសេវ សព្វាវុធ និង យោធូបករណ៍

ត- សារព័ត៌មាន និងទស្សនាវដ្តីថ្មីៗ និង

ថ- បារី ។

## ជំពូកទី ៣

## នីតិវិធី

(PROCEDURES)

### ប្រការ ៤ : លក្ខខណ្ឌទូទៅ (General Conditions)

៤.១: ឯកសារចម្លងបញ្ជាទិញ (Copies of Orders)

អ្នកនាំចូលទាំងឡាយត្រូវផ្តល់ជូនក្រុមហ៊ុនអធិការកិច្ច នូវឯកសារចម្លងបញ្ជាទិញនីមួយៗចំនួនពីរច្បាប់ សំរាប់រាល់ការទិញ ឬការនាំចូលទំនិញដូចៗ ។ ឯកសារដែលត្រូវដាក់មានពាក្យស្នើសុំទៅក្រុមហ៊ុនអធិការកិច្ចដែលបំពេញដោយអ្នកនាំចូល ដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធផ្លូវការ ដូចជាវិក្កយបត្របណ្តោះអាសន្ន លិខិតបញ្ជាទិញ កិច្ចសន្យាដែលបញ្ជាក់ ពីយថាប្រភេទនៃកិច្ចសន្យា ឯកសារដឹកជញ្ជូន និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ។

**៤.២: ការចេញលិខិតបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក** (Issue of PIO)

ការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ច ត្រូវចុះបញ្ជីនូវរាល់ការបញ្ជាទិញទំនិញទាំងនេះ ហើយត្រូវចេញលិខិតបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក ដែលនឹងត្រូវប្រគល់ជូនអ្នកនាំចូលក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង បន្ទាប់ពីបានទទួលបែបបទពីអ្នកនាំចូល ។

**៤.៣: លេខសំគាល់** (Reference Number)

លិខិតបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PIO) ត្រូវមានលេខសំគាល់ពិសេសមួយ ដើម្បីបញ្ជាក់កិច្ចការជំនួញ និងអាចត្រូវប្រើប្រាស់ក្នុងលិខិតឆ្លងឆ្លើយជាមួយនឹងក្រុមហ៊ុនអធិការកិច្ច ។

**៤.៤: ឯកសារមិនគ្រប់លក្ខណៈ** (Inadequate Documentation)

ឯកសារទាំងឡាយដែលអ្នកនាំចូលបានផ្ញើជូនក្រុមហ៊ុនអធិការកិច្ចដោយអ្នកនាំចូល ហើយត្រូវបានចាត់ថាជា ឯកសារមិនគ្រប់លក្ខណៈ មិនអាចអានបាន ឬមិនច្បាស់លាស់ ត្រូវតែបញ្ជូនត្រឡប់ជូនអ្នកនាំចូលវិញ ដើម្បីធ្វើការកែតំរូវ មុនពេលចេញលិខិតបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PIO) ។

**៤.៥: ការស្នើសុំព័ត៌មាន** (Request for Information)

ការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ច ត្រូវផ្ញើលិខិតបញ្ជាឱ្យធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកយ៉ាងលម្អិតទៅកាន់ការិយាល័យរបស់ក្រុមហ៊ុនអធិការកិច្ច ឬសាខារបស់ខ្លួននៅក្នុងប្រទេសដែលផ្គត់ទំនិញ ហើយការិយាល័យនោះ ត្រូវធ្វើសេចក្តីស្នើជាបន្ទាន់ជូនអ្នកលក់ ដើម្បីឱ្យផ្តល់ព័ត៌មានអំពីមុខទំនិញ និងរៀបចំចាត់ចែងធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

**៤.៦: របាយការណ៍ជូនទីចាត់ការគយ និងរដ្ឋាករ** (Reporting to Customs)

បន្ទាប់ពីពេលចេញរបាយការណ៍ជាក់ស្តែង (ROF) ក្រុមហ៊ុនអធិការកិច្ចត្រូវផ្ញើច្បាប់ចម្លងនៃរបាយការណ៍នេះ និងផ្ញើតាមអ៊ីម៉ែលដោយឥតពន្យារពេល ជូនទីចាត់ការគយ និងរដ្ឋាករដោយផ្ទាល់ ។

**៤.៧: ការត្រួតពិនិត្យឯកសារ** (Documentary Checks)

នីតិវិធីដែលត្រូវអនុវត្តដែលពាក់ព័ន្ធនឹងការនាំចូលដែលតម្រូវឱ្យមានការត្រួតពិនិត្យឯកសារ ដូចមានកំណត់និយមន័យនៅក្នុងជំពូកទី ១ ប្រការ ១ ចំណុច ១-៤ គឺដូចគ្នានឹងបញ្ញត្តិ

ដែលមាននៅក្នុងប្រការនេះ ដោយអ្នកលក់ត្រូវបានស្នើសុំឱ្យផ្ដល់ព័ត៌មាន និងឯកសារចុងក្រោយតាមទម្រង់កំណត់ ។ ចំណុចដែលខុសគ្នាតែមួយគត់ គឺពុំមានការធ្វើអធិការកិច្ចជាក់ស្ដែងផ្ទាល់ចំពោះទំនិញពាក់ព័ន្ធដោយក្រុមហ៊ុនអធិការកិច្ច ឬក្រុមហ៊ុនសាខារបស់ខ្លួននៅក្នុងប្រទេសផ្គត់ផ្គង់ទំនិញនៅមុនពេលផ្ទុក។

## ប្រការ ៥ : អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI of Goods)

### ៥.១: <u>អធិការកិច្ចទំនិញមុនពេលផ្ទុក</u> (PSI)

នៅពេលដែលទំនិញត្រូវបានរៀបចំរួចរាល់ហើយសំរាប់ធ្វើអធិការកិច្ច អ្នកលក់ត្រូវមកទាក់ទងជាមួយក្រុមហ៊ុនអធិការកិច្ចយ៉ាងតិច ៣(បី) ថ្ងៃមុន (ថ្ងៃធ្វើការ) ដើម្បីឱ្យក្រុមហ៊ុនអធិការកិច្ចរៀបចំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។ ទោះបីអ្នកលក់ជូនដំណឹងក្នុងរយៈពេលតិចជាង ៣(បី) ថ្ងៃ (ថ្ងៃធ្វើការ) ក៏ដោយ ក៏ក្រុមហ៊ុនអធិការកិច្ចត្រូវប្រញាប់ធ្វើអធិការកិច្ចទំនិញមុន្នពេលផ្ទុក (PSI) ។

### ៥.២: <u>កិច្ចការដែលត្រូវអនុវត្ត</u> (Required Tasks)

ក្រុមហ៊ុនអធិការកិច្ច ឬសាខារបស់ខ្លួននៅក្នុងប្រទេសផ្គត់ផ្គង់ទំនិញត្រូវបំពេញការងារពាក់ព័ន្ធទៅនឹងទំនិញ ដូចខាងក្រោមនេះ ដោយប្រើប្រាស់ព័ត៌មានទាំងអស់ដែលខ្លួនមាន :

**ក**- អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI)

**ខ**- ការផ្ទៀងផ្ទាត់ថ្លៃទំនិញ

**គ**- ការផ្ទៀងផ្ទាត់តម្លៃសរុបនៃទំនិញ

**ឃ**- ការកំណត់តម្លៃគិតពន្ធ និងតម្លៃទំនិញសមស្រប យោងតាមតារាងពន្ធគយកម្ពុជា និងនីតិវិធីកំណត់តម្លៃគយជាធរមាន និង

**ង**- ការគណនាពន្ធគយ និងអាករលើទំនិញដែលត្រូវបង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

### ៥.៣: <u>ឯកសារដែលត្រូវផ្ដល់ជូន</u> (Documentation to be Provided)

អ្នកលក់ត្រូវផ្ដល់ឱ្យក្រុមហ៊ុនអធិការកិច្ច ឬសាខារបស់ក្រុមហ៊ុនអធិការកិច្ច នូវឯកសារចម្លងនៃលិខិតបញ្ជាទិញ បញ្ជីតម្លៃទំនិញ សារឥណទាន និងឯកសារផ្សេងៗទៀតទាំងអស់ដែលក្រុមហ៊ុនអធិការកិច្ចត្រូវការចាំបាច់សំរាប់ការងារអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៩.៤: **ការបង្កលក្ខណៈងាយស្រួល** (Provision of Facilities)

អ្នកលក់ត្រូវបង្កលក្ខណៈងាយស្រួលឱ្យក្រុមហ៊ុនអធិការកិច្ច ឬ សាខារបស់ក្រុមហ៊ុនអធិការកិច្ចតាមសំណូមពរចាំបាច់នានាដូចជា វិញ្ញាបនប័ត្រធ្វើតេស្តទំនិញដើម្បីឱ្យក្រុមហ៊ុនអធិការកិច្ចអាចធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកបាន ។ អ្នកលក់ត្រូវរៀបចំប្រគល់បង្ហាញមុខទំនិញ និងបង្ហាញគំរូទំនិញព្រមទាំងកន្លែងធ្វើតេស្តទំនិញ ដើម្បីឱ្យស្របតាមគោលបំណងអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ។

៩.៥: **ទីកន្លែងធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក** (Place of PSI)

អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) អាចអនុវត្តនៅក្នុងទីបរិវេណរបស់អ្នកលក់ ឬកន្លែងសមរម្យណាមួយ មុនពេលដឹកជញ្ជូនទំនិញចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រុមហ៊ុនអធិការកិច្ចមានសិទ្ធិធ្វើអធិការកិច្ច ទំនិញឡើងវិញនៅគ្រប់ពេលវេលា ក្នុងរយៈពេលផ្គត់ផ្គង់ ឬប្រគល់នៅមុនពេលរៀបចំធ្វើការដឹកជញ្ជូនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

៩.៦: **ប្រថាប់ត្រាបិទលើកុងតឺន័រ** (Sealing of Containers)

ក្រុមហ៊ុនអធិការកិច្ចត្រូវបិទលេខសំគាល់ ហើយប្រថាប់ត្រាសំគាល់លើកុងតឺន័រដឹកទំនិញពេញទាំងអស់ (FCL) ដែលក្រុមហ៊ុនបានពិនិត្យរួច ។ លេខត្រា និងលេខកុងតឺន័រត្រូវបញ្ចូលទៅក្នុងរបាយការណ៍ជាក់ស្តែងដែលត្រូវចេញឱ្យ ។

៩.៧: **ការពិនិត្យឡើងវិញដោយក្រុមហ៊ុនអធិការកិច្ច** (Repeated Visits by Inspection Company)

អ្នកនាំចូលត្រូវប្រាប់អ្នកលក់ទំនិញអំពីលក្ខខណ្ឌនៃកម្មវិធីអធិការកិច្ចទំនិញមុនពេលផ្ទុក ។ ក្រុមហ៊ុនអធិការកិច្ច និងអ្នកលក់ត្រូវសហការគ្នាដើម្បីធានាអនុវត្តកម្មវិធីអធិការកិច្ចទំនិញមុនពេលផ្ទុកឱ្យប្រព្រឹត្តទៅបានល្អ ។

បើសិនអ្នកលក់ចាត់ចែងឱ្យក្រុមហ៊ុនអធិការកិច្ចធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក ដោយមិនបានរៀបចំទំនិញដែលត្រូវធ្វើអធិការកិច្ចនោះឱ្យបានត្រឹមត្រូវឬប្រសិនបើទំនិញនោះត្រូវបានផ្ទៀងផ្ទាត់ និងបានរកឃើញថា មានភាពមិនសមស្របគ្នាជាមួយនឹងសេចក្តីបញ្ជាក់អំពីប្រភេទនៃមុខទំនិញរបស់អ្នកនាំចូលនោះ អ្នកលក់នឹងត្រូវបង់សោហ៊ុយលើការចំណាយលើការចុះធ្វើការត្រួតពិនិត្យឡើងវិញនេះ និងអធិការកិច្ចទំនិញមុនពេលផ្ទុកឱ្យក្រុមហ៊ុនអធិការកិច្ច ។

៥.៨: **ករណីគ្មានលទ្ធភាពធ្វើអធិការកិច្ច** (Inability to Inspect)

ក្នុងករណីណាដែលក្រុមហ៊ុនអធិការកិច្ច មិនអាចមានលទ្ធភាពធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុកទេ នោះក្រុមហ៊ុនអធិការកិច្ចត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់ទីចាត់ការគយ និងរដ្ឋាករ ។

៥.៩: **វិក្កយប័ត្រស្ថាពរ** (Final Settlement Invoice)

នៅពេលមានការឯកភាពលើអធិការកិច្ចទំនិញមុនពេលផ្ទុក និងការផ្ទៀងផ្ទាត់ថ្លៃទំនិញ ដោយក្រុមហ៊ុនអធិការកិច្ច ឬសាខាក្រុមហ៊ុនអធិការកិច្ចនោះ អ្នកលក់ត្រូវចេញវិក្កយបត្រពាណិជ្ជកម្មស្ថាពរ ប័ណ្ណដឹកជញ្ជូន ប័ណ្ណដឹកជញ្ជូនតាមយន្តហោះ និងឯកសារដឹកជញ្ជូនផ្សេងៗទៀតជូនក្រុមហ៊ុនអធិការកិច្ច ។ ការទទួលឯកសារទាំងនេះមិនត្រូវជាលក្ខខណ្ឌក្នុងការចេញរបាយការណ៍ជាក់ស្តែង (ROF) ដោយក្រុមហ៊ុនអធិការកិច្ចឡើយ ។

វិក្កយបត្រស្ថាពរត្រូវមានខ្លឹមសារលម្អិតដូចខាងក្រោម :

ក- ការរៀបរាប់អំពីមុខទំនិញ ( តម្លៃដែលត្រូវបង់ ព័ត៌មានផ្សេងទៀត ដូចជាលក្ខខណ្ឌ នៃការទូទាត់ជាដើម )

ខ- ទំងន់ និងចំណុះ

គ- មធ្យោបាយដឹកជញ្ជូន

ឃ- កំពង់ផែ ឬព្រលានយន្តហោះដែលត្រូវផ្ទុកទំនិញ (រួមទាំងកំពង់ផែឆ្លងកាត់)

ង- កំពង់ផែ ឬព្រលានយន្តហោះដែលត្រូវដាក់ទំនិញចុះ និង

ច- កាលបរិច្ឆេទកំណត់នៃការដឹកជញ្ជូនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥.១០: **ការហាមឃាត់លើការប្រៀបធៀបថ្លៃ** (Price Verification Restrictions)

នៅក្នុងប្រទេសណាដែលការប្រៀបធៀបថ្លៃត្រូវបានហាមឃាត់តាមផ្លូវច្បាប់ ការផ្ទៀងផ្ទាត់ថ្លៃត្រូវអនុវត្តតាមច្បាប់ជាធរមានរបស់ប្រទេសនោះ ហើយក្រុមហ៊ុនអធិការកិច្ចត្រូវធ្វើរបាយការណ៍អំពីការហាមឃាត់ទាំងអស់នោះជូនទីចាត់ការគយ និងរដ្ឋាករ ។

## ប្រការ ៦ : នីតិវិធីនៃការយកទំនិញចេញ និងអធិការកិច្ចជាចុងក្រោយ
(Post-Inspection and Clearance Procedures)

### ៦.១: ការផ្តល់ជូនរបាយការណ៍ជាក់ស្តែង (Issue of ROF)

នៅពេលការងារអធិការកិច្ចទំនិញមុនពេលផ្ទុកបានអនុវត្តត្រឹមត្រូវរួច ក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់របាយការណ៍ជាក់ស្តែង (ROF) ជូនអ្នកនាំចូល ។

### ៦.២: មាតិកានៃរបាយការណ៍ជាក់ស្តែង (Contents of a ROF)

របាយការណ៍ជាក់ស្តែង ដែលចេញដោយក្រុមហ៊ុនអធិការកិច្ច ត្រូវមានព័ត៌មានសំខាន់ៗ ដូចតទៅ :

ក- ប្រភេទនៃទំនិញ

ខ- ចំនួន ឬបរិមាណទំនិញ

គ- គុណភាព ឬសេចក្តីបញ្ជាក់យថាប្រភេទជាក់ស្តែងនៃទំនិញ

ឃ- ការផ្ទៀងផ្ទាត់ថ្លៃទំនិញ

ង- ចំណាត់ថ្នាក់ទំនិញតាមតារាងពន្ធគយកម្ពុជា

ច- ប្រាក់ពន្ធ និងអាករទាំងឡាយដែលត្រូវបង់

ឆ- លេខកុងតឺន័រ និងលេខត្រា (Seal) សំរាប់ទំនិញដឹកជញ្ជូនតាមកុងតឺន័រ និង

ជ- អត្រាប្តូរប្រាក់

### ៦.៣: ឯកសារចម្លងនៃរបាយការណ៍ជាក់ស្តែង (Copies of ROF)

ក្រុមហ៊ុនអធិការកិច្ចត្រូវធ្វើរបាយការណ៍ជាក់ស្តែងឱ្យបានគ្រប់ចំនួន ដែលក្នុងនោះមានច្បាប់ដើមមួយច្បាប់ និងច្បាប់ចម្លងប្រាំច្បាប់ ។ ក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់ឱ្យអ្នកនាំចូលនូវច្បាប់ដើមមួយច្បាប់ និងច្បាប់ចម្លងបីច្បាប់ ។ ច្បាប់ចម្លងមួយច្បាប់ត្រូវផ្ញើជូនគយ និងច្បាប់ចម្លងមួយច្បាប់ទៀតត្រូវរក្សាទុកដោយក្រុមហ៊ុនអធិការកិច្ច ។

### ៦.៤: របាយការណ៍មិនស្របគ្នា (របាយការណ៍ជាក់ស្តែងមិនអាចតវ៉ាបាន)
Discrepancy Report (Non Negotiable Report of Findings)

ក្នុងករណីដែលអធិការកិច្ចទំនិញមុនពេលផ្ទុកមិនបានទទួលការឯកភាព ឬមិនសំរេចទាក់ទងនឹងបរិមាណ ឬគុណភាពទំនិញនោះ ក្រុមហ៊ុនអធិការកិច្ចមិនអាចចេញរបាយការណ៍ជាក់ស្តែង (ROF) បានឡើយ ។ ផ្ទុយទៅវិញក្រុមហ៊ុនអធិការកិច្ចត្រូវចេញរបាយការណ៍មិនស្របគ្នាហើយត្រូវផ្ញើជូនកន្លែងនានាស្របតាមជំពូកទី ៣ ប្រការ ៦ ចំណុច ៦.៣ ។

**៦.៥: <u>ការកែតម្រូវលើភាពមិនស្របគ្នា</u>** (Correction of Discrepancies)

ប្រសិនបើ អ្នកលក់មិនបានធ្វើការកែតម្រូវ ចំពោះភាពមិនស្របគ្នា ឱ្យបានទាន់ពេលវេលានៅមុនពេលដឹកជញ្ជូនទំនិញ ក្រុមហ៊ុនអធិការកិច្ច ត្រូវរក្សាទុកនូវរបាយការណ៍ជាក់ស្តែង (ROF) ហើយត្រូវចេញសេចក្តីបញ្ជាក់លើមុខទំនិញដែលមិនស្រប និងមិនបានកែតម្រូវ តាមរយៈរបាយការណ៍មិនស្រប ។ ប្រសិនបើអ្នកលក់យល់ព្រមកែតម្រូវតាមរបាយការណ៍ស្របគ្នាមុនពេលធ្វើការដឹកជញ្ជូនទំនិញនោះ ក្រុមហ៊ុនអធិការកិច្ចត្រូវផ្តល់របាយការណ៍ជាក់ស្តែង (ROF) ជូនអ្នកនាំចូល ។

**៦.៦: <u>ផ្លាកសញ្ញាសុវត្ថិភាព</u>** (Security Label)

ចំពោះការដឹកជញ្ជូនទំនិញនីមួយៗអ្នកលក់ត្រូវបានទទួលពីក្រុមហ៊ុនអធិការកិច្ចនូវច្បាប់ដើមនៃវិក្កយបត្រស្ថាពរ ដែលបានដាក់ជូនក្រុមហ៊ុនអធិការកិច្ច ដោយមានសេចក្តីបញ្ជាក់យ៉ាងត្រឹមត្រូវពីក្រុមហ៊ុនអធិការកិច្ច តាមរយៈផ្លាកសញ្ញាសុវត្ថិភាពដោយបញ្ជាក់ថា មុខទំនិញដែលមានចុះក្នុងវិក្កយបត្រត្រូវបានធ្វើអធិការកិច្ច ហើយរបាយការណ៍ជាក់ស្តែង (ROF) ក៏បានចេញជូនផងដែរ ។

**៦.៧: <u>ប្រតិវេទន៍គយ</u>** (Customs Declaration "CD")

អ្នកនាំចូលត្រូវប្រើរបាយការណ៍ជាក់ស្តែង (ROF) ជាគោលសំរាប់បំពេញប្រតិវេទន៍គយ និងទូទាត់ពន្ធគយ និងអាករដែលត្រូវបង់ជូនសមត្ថកិច្ចគយ និងរដ្ឋាករ ។ ក្នុងករណីមានការកែប្រែលើអត្រាពន្ធបន្ទាប់ពីចេញរបាយការណ៍ជាក់ស្តែង ហើយមុនពេលយកទំនិញចេញ អ្នកនាំចូលត្រូវយករបាយការណ៍ជាក់ស្តែង (ROF) មកជូនក្រុមហ៊ុនអធិការកិច្ចកែឡើងវិញយោងតាមការកែប្រែនោះ ។

**៦.៨: <u>អត្រាប្តូរប្រាក់</u>** (Rate of Exchange)

អត្រាប្តូរប្រាក់ដែលប្រើក្នុងរបាយការណ៍ជាក់ស្តែង (ROF) ត្រូវមានសុពលភាពរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃគិតចាប់ពីថ្ងៃចេញរបាយការណ៍ជាក់ស្តែង(ROF) ។ ប្រសិនបើប្រតិវេទន៍គយត្រូវបានផ្តល់បន្ទាប់ពីរយៈពេល ១៥ ថ្ងៃ អត្រាប្តូរប្រាក់ដែលមានជាធរមាននៅពេលផ្តល់ប្រតិវេទន៍គយនោះត្រូវយកមកប្រើ ។

**៦.៩: <u>ការផ្តល់នូវប្រតិវេទន៍គយ</u>** (Submission of CD)

អ្នកនាំចូល ឬអ្នកតំណាងស្របច្បាប់ ត្រូវផ្តល់ប្រតិវេទន៍គយជូនទីចាត់ការគយ និង រដ្ឋាករ

ដោយមានភ្ជាប់ទាំងឯកសារពាក់ព័ន្ធ ដែលរួមទាំងរបាយការណ៍ជាក់ស្តែង (ROF) និងត្រូវបង់ពន្ធគយ និងអាករផ្សេងៗដូចមានបញ្ជាក់ក្នុងប្រតិវេទន៍គយ ។

៦.១០: **អធិការកិច្ចទំនិញសារជាថ្មីឡើងវិញ** (Re-Inspection)

តាមសំណើរបស់ទីចាត់ការគយ និងរដ្ឋាករ ឬកាំកុងត្រូល BIVAC ត្រូវចាត់ការធ្វើអធិការកិច្ចរួមគ្នាជាថ្មីឡើងវិញជាមួយមន្ត្រីគយ និងកាំកុងត្រូល នៅពេលដែលទំនិញទាំងនោះបាននាំចូលមកដល់ព្រះរាជាណាចក្រកម្ពុជា ។ អធិការកិច្ចទាំងនេះអាចជាតំរូវការចាំបាច់ដោយសារការចេញរបាយការណ៍មិនសមស្របគ្នា ( របាយការណ៍ជាក់ស្តែងមិនអាចតវ៉ាបាន ) បើសិនជាមានហេតុផលសមស្របគួរឱ្យជឿជាក់បានថាទំនិញនោះ មិនស្របនឹងរបាយការណ៍ជាក់ស្តែង (ROF) ឬទំនិញនោះបានគេចវេសពីការធ្វើអធិការកិច្ចទំនិញ មុនពេលផ្ទុក (PSI) នៅឯប្រទេសផ្គត់ផ្គង់ទំនិញ ។ អធិការកិច្ចសារជាថ្មីឡើងវិញក៏អាចស្នើឡើងបានដោយអ្នកនាំចូលដែរ ។

## ជំពូកទី ៤

## កម្រៃអធិការកិច្ច

## (INSPECTION FEES)

### ប្រការ ៧ : កម្រៃ (Fees)

៧.១: **ចំនួនប្រាក់កម្រៃ** (Amount of Fee)

ទំនិញទាំងឡាយ ដែលមានបំណងត្រូវនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវចូលជាធរមានចាប់ពីថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៦ លើកលែងតែទំនិញក្នុងជំពូកទី ១ ប្រការ ១ ចំណុច ១.៥ ត្រូវបង់កម្រៃអធិការកិច្ច ដូចតទៅ:

**កម្មវិធីទី ១ : អធិការកិច្ចទំនិញមុនពេលផ្ទុកពេញលេញ (Full PSI)**

(ក) **ទំនិញផ្ទុកក្នុងកុងតឺន័រ** (Containerized Cargo)

(I) ទំនិញផ្ទុកក្នុងកុងតឺន័រពេញ (Full Container Load "FCL") មានរូបមន្ត BIVAC :

- ២០០ ដុល្លារអាមេរិក (ពីររយ) ក្នុងមួយកុងតឺន័រផ្ទុកទំនិញទំហំម្ភៃហ្វូត (ក្នុងមួយឯកតារង្វាស់ស្មើម្ភៃហ្វូត Twenty-Foot Equivalent Unite "T.E.U")
- ៩០ ដុល្លារអាមេរិក (កៅសិប) ក្នុងមួយកុងតឺន័រ T.E.U បន្ថែម ដោយមានកម្រៃសេវាជាអតិបរមាគឺ ៥០០ ដុល្លារអាមេរិក (ប្រាំរយ) ក្នុងរបាយការណ៍ជាក់ស្តែងមួយ ។
- ២៥០ ដុល្លារអាមេរិក (ពីររយហាសិប) ក្នុងមួយកុងតឺន័រផ្ទុកទំនិញទំហំសែសិបហ្វូត (Forty Foot) ឬ ច្រើនជាងសែសិបហ្វូត និង
- ១០០ ដុល្លារអាមេរិក (មួយរយ) ក្នុងមួយកុងតឺន័រផ្ទុកទំនិញទំហំសែសិបហ្វូតបន្ថែម ឬច្រើនជាងនេះ ដោយមានកម្រៃសេវាយ៉ាងច្រើនបំផុត ៥០០ ដុល្លារអាមេរិក( ប្រាំរយ )ក្នុងរបាយការណ៍ជាក់ស្តែងមួយ ។

(II) **<u>ទំនិញតិចជាងមួយកុងតឺន័រ</u>** <u>(Less than Container Loads "LCL")</u>

- ១៨០ ដុល្លារអាមេរិក (មួយរយប៉ែតសិប) ក្នុងពេលធ្វើអធិការកិច្ចម្តង និងមានរបាយការណ៍ជាក់ស្តែងមួយ ។

(ខ) **<u>ទំនិញមិនផ្ទុកក្នុងកុងតឺន័រ</u>** (Non Containerized Cargo)

(I) **<u>គេលសិលាមានបរិមាណច្រើន ឬវត្ថុរាវមានបរិមាណច្រើនដទៃទៀត</u>** (Bulk Petroleum ad Other Bulk Liquid)

- ០,២០ ដុល្លារអាមេរិក (ម្ភៃសេន) ក្នុងមួយតោន ហើយអប្បបរមាត្រឹម ១៨០ ដុល្លារអាមេរិក (មួយរយប៉ែតសិប) ក្នុងរបាយការណ៍ជាក់ស្តែងមួយ ។

(II) **<u>ផលិតផលមិនរាវមានបរិមាណច្រើនដទៃទៀត</u>** (Other Bulk, Non Liquid Products)

- ០,៣០ ដុល្លារអាមេរិក (សាមសិបសេន) ក្នុងមួយតោន ហើយអប្បបរមាត្រឹម ១៨០ ដុល្លារអាមេរិក (មួយរយប៉ែតសិប) ក្នុងរបាយការណ៍ជាក់ស្តែងមួយ ។

(III) **<u>ទំនិញរាយផ្សេងៗទៀត</u>** (Other Loose Cargo)

- ១៨០ ដុល្លារអាមេរិក (មួយរយប៉ែតសិប) ក្នុងពេលធ្វើការអធិការកិច្ចម្តង និងមានរបាយការណ៍មួយ ។

កម្មវិធីទី ២ : ការត្រួតពិនិត្យឯកសារ ( Documentary Check )

- ៧៥ ដុល្លារអាមេរិក ( ចិតសិបប្រាំ) សំរាប់ទំនិញមួយមុខ និង
- ៣០ ដុល្លារអាមេរិក (សាមសិប) ក្នុងមុខទំនិញបន្ថែមនិមួយៗ ហើយអតិបរមាត្រឹម ២០០ ដុល្លារ អាមេរិក ( ពីររយ) សំរាប់របាយការណ៍ជាក់ស្តែងមួយ ។

ក្រុមហ៊ុនអធិការកិច្ចមានសិទ្ធិទទួលបានកម្រៃសេវារបស់ខ្លួន ទោះបីក្នុងករណីដែលក្រោយពីការធ្វើអធិការកិច្ចទំនិញរួចរាល់ហើយ អ្នកនាំចេញ ឬអ្នកនាំចូលមិនបានផ្តល់ព័ត៌មាន ឬឯកសារចាំបាច់នានាសំរាប់ចេញរបាយការណ៍ជាក់ស្តែង (ROF) ក៏ដោយ ឬទោះបីមូលហេតុនៃការដឹកជញ្ជូនទំនិញមិនអាចដំណើរការទៅបានក៏ដោយ ។

៧.២: ការបង់កម្រៃ (Payment of Fees)

ប្រាក់កម្រៃត្រូវបង់ចូលធនាគារសាធារណៈកម្ពុជាចំកាត់នៅភ្នំពេញ (Cambodian Public Bank Limited) ដែលមានអាស័យដ្ឋានផ្ទះលេខ ២៣ ផ្លូវក្រមួនស សង្កាត់ផ្សារថ្មីទី ២ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ កម្ពុជា តាមគណនី PSI ដែលបានជ្រើសរើស ក្រោយពីការបំពេញបែបបទនាំចូលទៅឱ្យការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ច ដើម្បីសុំចេញបញ្ជាធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក ( PIO ) ។

៧.៣: ការចេញបង្កាន់ដៃបង់ប្រាក់ (Receipt to be Issued)

ពេលទទួលប្រាក់កម្រៃអធិការកិច្ច ធនាគារសាធារណៈកម្ពុជាចំកាត់ភ្នំពេញ ត្រូវចេញបង្កាន់ដៃបង់ប្រាក់ជូនអ្នកនាំចូល ។ អ្នកនាំចូលត្រូវដាក់ជូនការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ចនូវបង្កាន់ដៃនេះ ដោយភ្ជាប់ជាមួយនូវឯកសារនាំចូលផ្សេងៗទៀត ។

## ជំពូកទី ៥

## ដំណោះស្រាយវិវាទ

(RESOLUTION OF DISPUTES)

### ប្រការ ៨ : ការវិវាទ (Disputes)

៨.១: ការពិភាក្សាជាមួយក្រុមហ៊ុនអធិការកិច្ច (Discussion with the Inspection Company)

អ្នកនាំចូលអាចធ្វើការដេញដោល ឬ ជំទាស់ទៅនឹងយោបល់របស់ក្រុមហ៊ុនអធិការកិច្ចលើ

រាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងមុខទំនិញរបស់ខ្លួនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ផ្ញើជូនការិយាល័យទំនាក់ទំនងនៃក្រុមហ៊ុនអធិការកិច្ចនៅភ្នំពេញ ។ ប្រសិនបើការវិវាទមិនត្រូវបានដោះស្រាយក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលដែលក្រុមហ៊ុនអធិការកិច្ចបានទទួលលិខិតជំទាស់ជាលាយលក្ខណ៍អក្សរ អ្នកនាំចូលអាចបញ្ជូនសំណុំរឿងនេះទៅគណៈកម្មាធិការដោះស្រាយវិវាទ (Appeal Committee) ។

៨.២: **ការបញ្ចេញទំនិញ** (Release of Goods)

នៅពេលគណៈកម្មាធិការដោះស្រាយវិវាទកំពុងធ្វើការពិនិត្យ និងពិចារណាលើសំណុំរឿងរបស់អ្នកនាំចូល នោះអ្នកនាំចូលអាចដាក់ពាក្យសុំមកទីចាត់ការគយ និងរដ្ឋាករ ដើម្បីសុំយកទំនិញចេញដោយត្រូវបង់ប្រាក់កក់ធានាតាមការសំរេចរបស់ទីចាត់ការគយ និងរដ្ឋាករ ។

## ជំពូកទី ៦

## ការបង្កើតគណៈកម្មាធិការដោះស្រាយវិវាទ

(ESTABLISHMENT OF APPEALS COMMITTEE)

### ប្រការ ៩ : គណៈកម្មាធិការដោះស្រាយវិវាទ

គណៈកម្មាធិការដោះស្រាយវិវាទមួយ ត្រូវបានបង្កើតឡើងដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យសារឡើងវិញលើសេចក្តីសំរេចនានារបស់ក្រុមហ៊ុនអធិការកិច្ចដែលមានការតវ៉ាជាលាយលក្ខណ៍អក្សរពីអ្នកនាំចូល ។ សមាសភាពរបស់គណៈកម្មាធិការដោះស្រាយវិវាទនេះនឹងត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ៧

## ភារកិច្ចរបស់អ្នកនាំចូល និងអ្នកលក់

(OBLIGATIONS OF IMPORTERS AND SELLERS)

### ប្រការ ១០ : ការអនុវត្តន៍បទបញ្ញត្តិដោយអ្នកនាំចូល (Compliance by Importer)

ការចេញរបាយការណ៍ជាក់ស្តែង (ROF) គឺជាភស្តុតាងមួយបញ្ជាក់ថា មុខទំនិញបានធ្វើអធិការកិច្ចមុនពេលផ្ទុករួចហើយ ។

ការចេញរបាយការណ៍ជាក់ស្តែង (ROF) មិនមែនអនុញ្ញាតឱ្យអ្នកនាំចូលរួចផុតពីភាតព្វកិច្ច របស់ខ្លួនក្នុងការគោរពច្បាប់ វិន័យ និងបទបញ្ញត្តិពាក់ព័ន្ធទៅនឹងការនាំចូល និងការលក់ ទំនិញនៅក្នុងព្រះរាជាណាចក្រកម្ពុជានោះឡើយ ។

**ប្រការ ១១ : ភាតព្វកិច្ចរបស់អ្នកលក់ចំពោះអ្នកទិញ** (Seller's Obligation to Importer)

អធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) ដែលអនុវត្តដោយក្រុមហ៊ុនអធិការកិច្ចនោះ ពុំមាន ឥទ្ធិពលអ្វីទៅលើសិទ្ធិរបស់អ្នកទិញទំនិញ ដើម្បីជំទាស់ជាមួយអ្នកលក់ ហើយក៏មិនអនុញ្ញាត ឱ្យអ្នកលក់ទំនិញរួចផុតពីការទទួលខុសត្រូវលើកិច្ចសន្យាចំពោះអ្នកនាំចូលទំនិញឡើយ ។

## ជំពូកទី ៨

## ការប្រព្រឹត្តិផ្ទុយនឹងបទបញ្ញត្តិ

(NON-COMPLIANCE)

**ប្រការ ១២ : ការពិន័យ** (Penalties)

បុគ្គលណាដែលខកខានពុំបានមកសុំធ្វើអធិការកិច្ចទំនិញមុនពេលផ្ទុក (PSI) នូវរាល់មុខ ទំនិញ លើកលែងតែទំនិញដែលមានចែងនៅក្នុងប្រការ ១ ចំណុច ១.៥ ដែលត្រូវដឹកជញ្ជូន ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវទទួលទណ្ឌកម្មយ៉ាងខ្លាំងពីអាជ្ញាធរមានសមត្ថកិច្ច ។

(៤)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤៣ ពណ.នគក

ភ្នំពេញថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ខេ.អាយ.ឌី**

**K . I . D Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8476/06P** ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **សួន ទិសិដ្ឋ** ប្រធានក្រុមប្រឹក្សាភិបាល

លោក **ទៅ សុវណ្ណសុធ្ធា** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ២៥៩ E1 ផ្លូវលេខ ១៥៦ សង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -អាជីវកម្មបូមខ្សាច់

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដឹកជញ្ជូនសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចាម ប្រសិទ្ធ**

**កើម សុីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ ✓
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៨៥ ពណ.នគក

ភ្នំពេញថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៦

## សេចក្តីប្រកាស រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អេស្តាត (ខេមបូឌា)**

**ESTARD ( CAMBODIA ) Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 2790/06E ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក TIAN SHENG ប្រធានក្រុមប្រឹក្សាភិបាល

លោក LI GUANGPENG អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៤០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ៦៥ B. ផ្លូវលេខ ១១១ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើនៅក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្តវីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋមន្ត្រីស្តីទី

**គឹម ស៊ីថន**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុំខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៧៦ ពណ.នគក

ភ្នំពេញថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

**ឆេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ចំប៉ា ខេមបូឌាន ហាឌរី**

**CHAMPA CAMBODIAN HADHARI Co.,Ltd**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 2798/06E** ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក CHE HAMID BIN CHE ALI ប្រធានក្រុមប្រឹក្សាភិបាល

លោក CHE BAHANUDDIN BIN CHE YOB អភិបាល

លោក **ម៉ាត់ ភាជី** អភិបាល

លោក **សុះ លីម៉ាន** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ភូមិ សំបួរ ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហ័រណ អាហារណទំនិញគ្រប់ប្រភេទ នាំចូល ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្មកែច្នៃផលិតផលកសិកម្ម ស្រូវ អង្ករ ពោត សណ្តែក

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកវត្ថុ ពាណិជ្ជកម្ម

-សេវាដឹកជញ្ជូនទំនិញផ្ទើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ ...

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
- សាលាខេត្តកំពង់ចាម
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម "មុខការ"
- ឯកសារ -កាលប្បវត្តិ

**ចាម ប្រសិទ្ធ**

**គឹម_ស៊ីថន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៥៤៤ ពណ.នគក

ភ្នំពេញថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ឡុង ហ័រ ត្រេឌីង អេន ធួរ**

**LONG HOA TRADING AND TOURS Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : **Co. 8477/06 P** ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក **ឃុក អួយឡុង**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៩៩ ផ្លូវលេខ ៦០៨ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-រោងពុម្ព -បោះពុម្ពផ្សាយ

-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ ឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ-ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកក់រៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកវិនិយោគ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-ផលិតខ្សែភាពយន្ត វីដេអូ ...

